**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
**ចៅក្រម "ខ"**

-សំណុំរឿងរដ្ឋប្បវេណីលេខ:២៦៨
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។
-សាលក្រមលេខ:០៨ (ង)
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០។

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅសាលាដំបូងខេត្តតាកែវ។
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។
កាលបរិច្ឆេទប្រកាសសាលក្រមនាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០។

**ចៅក្រម:លោក [redacted]**
**ក្រឡាបញ្ជី:លោកស្រី [redacted]**
**លោក [redacted] និងលោក [redacted] ជាមេធាវីតំណាង**
**ដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted]។**
**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖**

រវាងដើមចោទ៖

-ឈ្មោះ [redacted] ស្ពាង ភេទស្រី អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅបច្ចុប្បន្ន [redacted]។

និងសហចុងចម្លើយ៖

១.ឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ភេទស្រី អាយុ ៣៦ឆ្នាំ និងប្ដីឈ្មោះ [redacted] ហៃឡុង អាយុ ៣៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted]។

២.ឈ្មោះ [redacted] ឈាង ភេទប្រុស មានទីលំនៅបច្ចុប្បន្ន [redacted]។

## អង្គហេតុនិងចំណុចវិវាទ៖

**១.សាលក្រមដែលទាមទារដោយដើមចោទ:**

ក.ប្ដឹងទាមទារប្រាក់ដើមចំនួន១,៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក) និងលុយខ្មែរចំនួន៨,៧៦០,០០០៛ (ប្រាំបីលានចិតសិបប្រាំមួយម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។

ខ.ទាមទារប្រាក់ដើមចំនួន ៣,៦០០,០០០៛ (បីលានហុកសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។

គ.ទាមទារប្រាក់ដើមចំនួន១៥,៨០០,០០០៛ (ដប់ប្រាំលានប៉ែតសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។



Scanned with CamScanner

ឃ.ទាមទារប្រាក់ដើមចំនួន១៤៧,៦៥៨,០០០៛ (មួយរយសែសិបប្រាំពីរលានហុកសិបប្រាំម៉ឺនប្រាំបីពាន់រៀល) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។

ង.ទាមទារអត្រាការប្រាក់ ២% (ពីរភាគរយ)ក្នុងមួយខែៗចាប់ពីថ្ងៃខ្ចីប្រាក់រហូតដល់ថ្ងៃសងគ្រប់ចំនួនពីសហចុងចម្លើយ។

ច.ទាមទារសំណងនៃការខូចខាត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗព្រមទាំងសេវាមេធាវីចំនួន ៥០,០០០,០០០៛ (សែសិបលានរៀល)។

ឆ.ទាមទារឱ្យមានការអនុវត្តជាបណ្ដោះអាសន្នចំពោះប្រាក់ដើមដែលមាននៅក្នុងចំណុច ក,ខ,គ និងចំណុច ឃ ខាងលើ។

ជ.ទាមទារឱ្យសហចុងចម្លើយរ៉ាប់រងនូវប្រាក់ប្រដាប់ក្ដី។

**២.ការពន្យល់ត្រួសៗអំពីរឿងក្ដី:**

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] ស្នាង ចំនួន ១,៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក) និងប្រាក់រៀលចំនួន ៨,៧៦០,០០០៛ (ប្រាំបីលានចិតសិបប្រាំមួយម៉ឺនរៀល) ក្រោយមកនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ក៏បានខ្ចីប្រាក់បន្ថែមទៀតចំនួន៣,៦០០,០០០៛ (បីលានហុកសិបម៉ឺនរៀល) ពីដើមចោទឈ្មោះ [redacted] ស្នាង និងចុងក្រោយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ក៏បានខ្ចីប្រាក់បន្ថែមចំនួន ១៥,៨០០,០០០៛ (ដប់ប្រាំលានប៉ែតសិបម៉ឺនរៀល) ទៀត។ ចំពោះការខ្ចីប្រាក់ចំនួនបីលើកខាងលើរវាងដើមចោទ និងចុងចម្លើយពុំបានធ្វើកិច្ចសន្យានោះទេ ដោយសារការខ្ចីប្រាក់នេះយកម្ដងបន្តិចៗ និងមានការទុកចិត្តគ្នាផងដែរ។ ចំពោះប្រាក់ចំនួន ១៤៧,៦៥៨,០០០៛ (មួយរយសែសិបប្រាំពីរលានហុកសិបប្រាំម៉ឺនប្រាំបីពាន់រៀល) ចុងចម្លើយឈ្មោះ[redacted]សុគន្ធារី ហៅ ស្រីពៅ ក៏បានខ្ចីពីដើមចោទឈ្មោះ [redacted] ស្នាង កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ផងដែរ ដោយបានធ្វើកិច្ចសន្យាចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ដោយសន្យាបង់ការប្រាក់ចំនួន៣,០០០,០០០៛ (បីលានរៀល) ក្នុងមួយខែ តែមកដល់បច្ចុប្បន្នចុងចម្លើយមិនព្រមសងនូវប្រាក់ដើម និងការប្រាក់មកឱ្យដើមចោទនោះទេ ទើបខ្លួនដាក់ពាក្យបណ្ដឹងមកសាលាដំបូងខេត្តតាកែវតែម្ដង។

**៣.ការអះអាងរបស់គូភាគី:**

-ដើមចោទឈ្មោះ [redacted] ស្នាង បានធ្វើសេចក្ដីថ្លែងការណ៍នាទីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ខ្លួនប្ដឹងសុំទាមទារនូវប្រាក់ដើមពីសហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ និងប្ដីឈ្មោះ [redacted] ហៃឡុង និងសហចុងចម្លើយឈ្មោះ [redacted]



Scanned with CamScanner

ឈាង នូវប្រាក់៖ក-ប្តឹងទាមទារប្រាក់ដើមចំនួន១,៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក) និងលុយខ្មែរចំនួន៨,៧៦០,០០០៛ (ប្រាំបីលានចិតសិបប្រាំមួយម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ខ-ទាមទារប្រាក់ដើមចំនួន៣,៦០០,០០០៛ (បីលានហុកសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ គ-ទាមទារប្រាក់ដើមចំនួន១៥,៨០០,០០០៛ (ដប់ប្រាំលានប៉ែតសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ឃ-ទាមទារប្រាក់ដើមចំនួន១៤៧,៦៥៨,០០០៛ (មួយរយសែសិបប្រាំពីរលានហុកសិបប្រាំម៉ឺនប្រាំបីពាន់រៀល) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ង-ទាមទារអត្រាការប្រាក់ ២% (ពីរភាគរយ)ក្នុងមួយខែៗចាប់ពីថ្ងៃខ្ចីប្រាក់រហូតដល់ថ្ងៃសងគ្រប់ចំនួនពីសហចុងចម្លើយ។ច-ទាមទារសំណងនៃការខូចខាត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗព្រមទាំងសេវាមេធាវីចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល)។ ឆ-ទាមទារឲ្យមានការអនុវត្តជាបណ្តោះអាសន្នចំពោះប្រាក់ដើមដែលមាននៅក្នុងចំណុច ក,ខ,គ និងចំណុច ឃ ខាងលើ។ និងជ-ទាមទារឲ្យសហចុងចម្លើយរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី។ ចំពោះការខ្ចីចងការប្រាក់ដែលមាននៅក្នុងចំណុច ក,ខ និងគ គឺពុំបានធ្វើកិច្ចសន្យានោះទេ ហើយក៏ពុំមានអ្នកណាធានាដែរ ដោយផ្អែកលើការទុកចិត្តគ្នា និងម្យ៉ាងទៀតការខ្ចីប្រាក់ទាំងបីចំណុចខាងលើគឺជាការយកប្រាក់បន្តិចម្តងៗ ទើបពុំមានកិច្ចសន្យា។ ចំណែកឯការខ្ចីនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ គឺមានចំនួនច្រើន ទើបនាងខ្ញុំឲ្យឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ធ្វើកិច្ចសន្យាខ្ចីហើយឈ្មោះនេះជាអ្នកសរសេរដោយផ្ទាល់ដៃតែម្តង និងមានអ្នកធានាជាឪពុកបង្កើតឈ្មោះ [redacted] ឈាង ដោយសន្យាថាបង់ការប្រាក់ក្នុងមួយខែចំនួន ៣,០០០,០០០៛ (បីលានរៀល) ជារៀងរាល់ខែ ប៉ុន្តែឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ពុំបានបង់ការប្រាក់ទេ ហើយតែងតែព្យាយាមគេចពីខ្លួនរហូត។ លើសពីនេះទៀតគាត់បានសន្យាសងក្នុងមួយថ្ងៃចំនួន ៥០,០០០៛ (ប្រាំម៉ឺនរៀល) ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ក៏ពុំបានបង់ប្រាក់នេះឲ្យទៀត។ ក្រោយមកឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ បានលក់ផ្ទះរបស់គាត់ដែលមានទីតាំងស្ថិតនៅភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ រួចហើយ គាត់នៅតែពុំព្រមសងនូវប្រាក់ដើម និងការប្រាក់មកខ្លួនឡើយ។ ហេតុដូច្នេះហើយទើបខ្លួនប្តឹងទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចនៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-សហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ប្តីឈ្មោះ [redacted] ហៃឡុង និងឈ្មោះ [redacted] ឈាង បានអវត្តមាននានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយ និងលើកទី២ តែលោកក្រឡាបញ្ជីបានធ្វើការបញ្ជូននូវដីកាកោះឲ្យទៅសហចុងចម្លើយរួចហើយកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយឈ្មោះ [redacted] សុផាន្នី ត្រូវជាប្អូនបានទទួលដីកាកោះជំនួស។

-សហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ មានវត្តមាននានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ហើយខ្លួនបានធ្វើសេចក្តីថ្លែងការណ៍ និងអះអាងថា៖ខ្លួនទទួលស្គាល់នូវបំណុល និងការប្រាក់ក៏ដូចជាការចំណាយផ្សេងៗរបស់ដើមចោទទាំងស្រុងដោយពុំមានអ្វីជំទាស់ និងការទាមទាររបស់ដើមចោទនោះទេ។

**៤.ចំណុចវិវាទ:**

-ដើមចោទនៅតែប្តឹងទាមទារប្រាក់ដូចមានក្នុងកម្មវត្ថុខាងលើដដែល។

-សហចុងចម្លើយទទួលស្គាល់ការជំពាក់ប្រាក់ដែលដើមចោទបានលើកឡើង តែសុំបដិសេធនូវការទាមទារសេវាមេធាវី។

-លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ឆ្លងតាមការទាញហេតុផលដោយផ្ទាល់មាត់នេះឃើញថាសហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី បានទទួលស្គាល់នូវការជំពាក់ប្រាក់របស់កូនក្តីខ្លួនដែលបានរៀបរាប់នៅក្នុងកម្មវត្ថុខាងលើ។ ដូច្នេះស្នើសុំតុលាការសម្រេចចេញសាលក្រមតាមការប្តឹងទាមទាររបស់កូនក្តីខ្លួនផង។

**សំអាងហេតុ**

១-តាមពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] ស្វាង ធ្វើឡើងស្របតាមទម្រង់ និងគតិច្បាប់ដោយអនុឡោមតាមបញ្ញត្តិមាត្រា ៧៤ និងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-តាមការអះអាងរបស់ភាគីដើមចោទនានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយ និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទនៅតែទាមទារឲ្យសហចុងចម្លើយសងប្រាក់មកឲ្យខ្លួនដូចមាននៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ដដែល។

៣-តាមការអះអាងរបស់ភាគីដើមចោទឈ្មោះ [redacted] ស្វាង និងសហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ នានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់សហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ ទទួលស្គាល់នៃការខ្ចី និងជំពាក់ប្រាក់ពីដើមចោទឈ្មោះ វណ្ណៈ ស្វាង ពិតប្រាកដមែន។

៤-តាមសេចក្តីថ្លែងការណ៍ និងការអះអាងរបស់ដើមចោទ និងសហចុងសម្លើយក៏ដូចជាការពិនិត្យភស្តុតាងឃើញថាសហចុងចម្លើយឈ្មោះ [redacted] សុគន្ធារី ហៅ ស្រីពៅ និងប្តីឈ្មោះ [redacted] ហៃឡុង និងសហចុងចម្លើយឈ្មោះ [redacted] ឈាង នៅជំពាក់ប្រាក់ដើមចំនួន៖ក.ប្រាក់ដើមចំនួន១,៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក) និងលុយខ្មែរចំនួន៨,៧៦០,០០០៛ (ប្រាំបីលានចិតសិបប្រាំមួយម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ខ.ប្រាក់ដើមចំនួន៣,៦០០,០០០៛ (បីលានហុកសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ គ.ប្រាក់ដើមចំនួន១៥,៨០០,០០០៛ (ដប់ប្រាំលានប៉ែតសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃ ទី១១ ខែតុលា ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ឃ.ប្រាក់ដើមចំនួន១៤៧,៦៥៨,០០០៛ (មួយរយសែសិបប្រាំពីរលានហុកសិបប្រាំម៉ឺនប្រាំបីពាន់រៀល)តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែសីហា

ឆ្នាំ២០១៩ ពីសហចុងចម្លើយ។ ការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវគប្បីតុលាការទទួលស្គាល់ការទាមទារនេះ។

៥-ដើមចោទប្តឹងទាមទារនូវអត្រាការប្រាក់ ២% (ពីរភាគរយ) ក្នុងមួយខែៗពីសហចុងចម្លើយចាប់ពីថ្ងៃខ្ចីប្រាក់រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួនវិញ។ ការទាមទាររបស់ដើមចោទគប្បីតុលាការទទួលយកមកពិចារណា និងសម្រេចតាមច្បាប់។

៦-ដើមចោទប្តឹងទាមទារនូវសំណងនៃការខូចខាត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗព្រមទាំងសេវាមេធាវីចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល)។ការទាមទារនេះ គប្បីតុលាការពិចារណាសម្រេចតាមស្ថានភាពជាក់ស្តែង។

៧-សហចុងចម្លើយឈ្មោះ [redacted] ហៃឡុង និងឈ្មោះ [redacted] ឈាង អវត្តមាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយពុំមានមូលហេតុសមរម្យគប្បីតុលាការសម្រេចតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៨-ដើមចោទទាមទារឲ្យមានការអនុវត្តជាបណ្តោះអាសន្នចំពោះប្រាក់ដើមដែលមាននៅក្នុងកម្មវត្ថុនៃបណ្តឹងទាមទារនៃចំណុច ក,ចំណុចខ ,ចំណុចគ និងចំណុច ឃ ខាងលើ។ ការទាមទាររបស់ដើមចោទមានហេតុផលសមស្របអាចឲ្យតុលាការពិចារណាបាន។

៩-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយដោយអនុលោមតាមបញ្ញត្តិមាត្រា៦៤ ចំណុច១នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **សុគន្ធារី ហៅ ស្រីពៅ** និងប្តីឈ្មោះ [redacted] **ហៃឡុង** និងសហចុងសម្លើយឈ្មោះ [redacted] **ឈាង** រួមគ្នាសងនូវប្រាក់ដើមឲ្យទៅដើមចោទនូវចំនួនប្រាក់ដូចខាងក្រោម៖

ក.ប្រាក់ដើមចំនួន១,៥០០ USD (មួយពាន់ប្រាំរយដុល្លារអាមេរិក)និងលុយខ្មែរចំនួន ៨,៧៦០,០០០៛ (ប្រាំបីលានចិតសិបប្រាំមួយម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៩ ពីដើមចោទ។

ខ.ប្រាក់ដើមចំនួន៣,៦០០,០០០៛ (បីលានហុកសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៩ ពីដើមចោទ។

គ.ប្រាក់ដើមចំនួន១៥,៨០០,០០០៛ (ដប់ប្រាំលានប៉ែតសិបម៉ឺនរៀល) ដែលបានខ្ចីកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ពីដើមចោទ។



Scanned with CamScanner

ឃ.ប្រាក់ដើមចំនួន១៤៧,៦៥៨,០០០៛ (មួយរយសែសិបប្រាំពីរលានហុកសិបប្រាំម៉ឺនប្រាំបីពាន់រៀល) តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ពីដើមចោទ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **សុគន្ធារី ហៅ ស្រីពៅ** និងប្តីឈ្មោះ [redacted] **ហៃឡុង** និងសហចុងចម្លើយឈ្មោះ [redacted] **ឈាង** រួមគ្នាសងនូវការប្រាក់ឱ្យទៅដើមចោទ ១,៥% ក្នុងមួយខែលើប្រាក់ដើមដោយគិតចាប់ពីថ្ងៃខ្ចីប្រាក់រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **សុគន្ធារី ហៅ ស្រីពៅ** និងប្តីឈ្មោះ [redacted] **ហៃឡុង** និងសហចុងចម្លើយឈ្មោះ [redacted] **ឈាង** រួមគ្នាសងនូវសំណងនៃការខូចខាត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗព្រមទាំងសេវាមេធាវីឱ្យទៅដើមចោទឈ្មោះ [redacted] **ស្អាង** ជាប្រាក់ចំនួន១០,០០០,០០០៛ (ដប់លានរៀល)។ ការទាមទារលើសពីនេះត្រូវច្រានចោល។

៤-សាលក្រមនេះមានអនុភាពអនុវត្តជាបណ្តោះអាសន្នចំពោះប្រាក់ដើមដែលមានចែងនៅក្នុងចំណុច ក,ចំណុច ខ,ចំណុច គ និងចំណុច ឃ ដូចមាននៅក្នុងកម្មវត្ថុនៃការទាមទារ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយស្របតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

តាកែវ,ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

តាកែវ,ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

តាកែវ,ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**ចៅក្រម**

[redacted]